**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...១៥១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់ស្នូលស្ទឹងសែននៃឋបនីយជីវមណ្ឌលបឹងទន្លេសាប និងតំបន់ដីសើមជុំវិញជា តំបន់រ៉ាមសារស្ទឹងសែន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៤ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី តំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជម្រកសត្វស្លាបទឹក ចុះនៅទីក្រុងរ៉ាមសារ ប្រទេសអ៊ីរ៉ង់ នាថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៧១
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងការគ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន



៩៥

## សម្រេច

**មាត្រា១.-**

ត្រូវបានកំណត់តំបន់ស្នូលស្ទឹងសែននៃឋបនីយជីវមណ្ឌលបឹងទន្លេសាប និងតំបន់ដីសើមជុំវិញ ជាតំបន់រ៉ាមសារស្ទឹងសែន មានផ្ទៃក្រឡាសរុប ៩.២៩៣ ហិកតា (ប្រាំបួនពាន់ពីររយកៅសិបបីហិកតា) ដែលមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្រឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដូចមានផែនទីមាត្រដ្ឋាន ១/៤០.០០០ ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ និងមាននិយាមកាគោល (Datum: WGS1984) ដូចខាងក្រោម៖

| និយាមកាគោល | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ID | X | Y | ID | X | Y | ID | X | Y | ID | X | Y |
| 1 | 448089 | 1391811 | 12 | 442905 | 1394286 | 23 | 447554 | 1404268 | 34 | 542048 | 1400000 |
| 2 | 447370 | 1390721 | 13 | 443441 | 1396407 | 24 | 447366 | 1403924 | 35 | 451961 | 1399518 |
| 3 | 446474 | 1389458 | 14 | 444052 | 1397738 | 25 | 447962 | 1402076 | 36 | 451223 | 1399058 |
| 4 | 445509 | 1388297 | 15 | 444373 | 1398651 | 26 | 449476 | 1402538 | 37 | 451394 | 1398370 |
| 5 | 444559 | 1388974 | 16 | 444913 | 1399022 | 27 | 451030 | 1402216 | 38 | 451714 | 1397823 |
| 6 | 444027 | 1389056 | 17 | 445279 | 1400053 | 28 | 451171 | 1401258 | 39 | 451824 | 1395197 |
| 7 | 443951 | 1389820 | 18 | 445780 | 1401187 | 29 | 451822 | 1400894 | 40 | 451257 | 1394677 |
| 8 | 443081 | 1390341 | 19 | 446047 | 1402561 | 30 | 451912 | 1401727 | 41 | 451031 | 1393300 |
| 9 | 443070 | 1391003 | 20 | 446199 | 1405107 | 31 | 452398 | 1401276 | 42 | 450375 | 1392457 |
| 10 | 443556 | 1392314 | 21 | 447360 | 1405576 | 32 | 452710 | 1401070 | 43 | 449419 | 1391820 |
| 11 | 442426 | 1393377 | 22 | 446582 | 1405676 | 33 | 453178 | 1401155 | | | |

ចំណុចនិយាមកាទាំងនេះ ប្រើប្រាស់សម្រាប់កំណត់ព្រំប្រទល់នៃតំបន់រ៉ាមសារស្ទឹងសែនតែប៉ុណ្ណោះ ពុំមានឥទ្ធិពលផ្លូវច្បាប់ទៅលើការកំណត់ព្រំប្រទល់រដ្ឋបាលឃុំ ស្រុក និងខេត្តឡើយ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ៖

- គាំទ្រការអភិរក្ស និងការការពារនៃតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ ស្របតាមអនុសញ្ញារ៉ាមសារ
- ជានាការថែរក្សា និងការពារសោភ័ណភាពធម្មជាតិ វប្បធម៌ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- រក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣.-**

ក្រសួងបរិស្ថាន ដែលមានអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ជាសេនាធិការ មានសមត្ថកិច្ច ក្នុងការរៀបចំ គ្រប់គ្រង ការពារ និងថែរក្សាតំបន់រ៉ាមសារស្ទឹងសែន ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**មាត្រា៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃសុក្រ ៩ រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទី តំបន់រ៉ាមសារស្ទឹងសែន ស្ថិតក្នុងខេត្តកំពង់ធំ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃ សុក្រ ៩ រោច ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ២០១៨




| ល.រ | X | Y |
|---|---|---|
| 1 | 448089 | 1391811 |
| 2 | 447370 | 1390721 |
| 3 | 446474 | 1389458 |
| 4 | 445509 | 1388297 |
| 5 | 444559 | 1388974 |
| 6 | 444027 | 1389056 |
| 7 | 443951 | 1389820 |
| 8 | 443081 | 1390341 |
| 9 | 443070 | 1391003 |
| 10 | 443556 | 1392314 |
| 11 | 442426 | 1393377 |
| 12 | 442905 | 1394286 |
| 13 | 443441 | 1396407 |
| 14 | 444052 | 1397738 |
| 15 | 444373 | 1398651 |
| 16 | 444913 | 1399022 |
| 17 | 445279 | 1400053 |
| 18 | 445780 | 1401187 |
| 19 | 446047 | 1402561 |
| 20 | 446199 | 1405107 |
| 21 | 447360 | 1405576 |
| 22 | 446582 | 1405676 |
| 23 | 447554 | 1404268 |
| 24 | 447366 | 1403924 |
| 25 | 447962 | 1402076 |
| 26 | 449476 | 1402538 |
| 27 | 451030 | 1402216 |
| 28 | 451171 | 1401258 |
| 29 | 451822 | 1400894 |
| 30 | 451912 | 1401727 |
| 31 | 452398 | 1401276 |
| 32 | 452710 | 1401070 |
| 33 | 453178 | 1401155 |
| 34 | 452048 | 1400000 |
| 35 | 451961 | 1399518 |
| 36 | 451223 | 1399058 |
| 37 | 451394 | 1398370 |
| 38 | 451714 | 1397823 |
| 39 | 451824 | 1395197 |
| 40 | 451257 | 1394677 |
| 41 | 451031 | 1393300 |
| 42 | 450375 | 1392457 |
| 43 | 449419 | 1391820 |




**ផ្ទៃដី តំបន់រ៉ាមសារស្ទឹងសែន សរុប ៩.២៩៣ ហិកតា**

ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅកំពង់ធំ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៨ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៨

អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ

សុខ-លូ

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់